ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម
# នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២
# (ខ្សែផ្លូវជីពាំង - ក្រសាំង) ស្រុកពញាក្រែក និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ)

## សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រតិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ ខេត្តកោះកុង និងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បី ទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពប្រែប្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការ ក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាននិងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 5: ខ្សែផ្លូវជីពាំង - ក្រសាំង) ដែលស្ថិតនៅក្នុងឃុំក្រែក និងឃុំទឹកជ្រៅ ក្នុងស្រុកពញាក្រែក និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ មានប្រវែង១៤,០៣៦ម៉ែត្រ និងទទឹងប្រវែង៨ម៉ែត្រ បាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីរជាន់និងបេតុងសរសៃដែក ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានដូចជាសំណង់លូមូលចំនួន២៣កន្លែង ក្នុងនោះសំណង់លូមូលចំនួន២កន្លែងគឺរក្សាទុកដដែល និងសំណង់លូមូល១៨កន្លែងត្រូវជួសជុលកសាងឡើងវិញ។ ក្រៅពីនេះសំណង់លូមូលចំនួន១កន្លែងត្រូវលុបចោល និងសាងសង់ថ្មីនៅសំណង់លូមូលចំនួន២កន្លែងបន្ថែម។ អនុគម្រោងនេះចាប់ផ្តើមដំណើរការសាងសង់ពីខែមិថុនា ឆ្នាំ២០២៣ រហូតដល់ខែឧសភា ឆ្នាំ២០២៤ ដោយក្រុមហ៊ុន ស៊ីកស្តារ ខនស្ត្រាក់សិន (6 Stars Construction Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ២,៣៧៣,៨១៦.២៤ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការសាងសង់។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ពុំមានប្រជាពលរដ្ឋដែលស្ថិតនៅសងខាងផ្លូវ ទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះឡើយ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវ រួមមានដើមឈើចំនួន៣៣ដើម ដែលជាទ្រព្យសម្បត្តិសាធារណៈនៃដីចំណីផ្លូវ។ ទន្ទឹមនឹងនេះដែរ រដ្ឋបាលស្រុកពញាក្រែក បានបញ្ជាក់ជាលាយល័ក្ខអក្សរពីការធានាអះអាងមិនប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សាជាសាធារណៈចំនួន២លើកបានរៀបចំឡើង។ ការពិភាក្សាជាសាធារណៈលើកទី១ បានធ្វើនៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៧៧នាក់ (ស្ត្រី៥នាក់) និងការពិភាក្សាជាសាធារណៈលើកទី២ នៅថ្ងៃទី១៣-១៤ ខែមីនា ឆ្នាំ២០២៣ មានប្រជាពលរដ្ឋចូលរួមចំនួន ១០៦នាក់ ក្នុងនោះមានស្ត្រី៣១នាក់។

ចំពោះយន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋអាចផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ។ យន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើង ដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយល័ក្ខអក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទ ឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលមានលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។